**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ សុក្រ ៦ កើត ខែ បឋមាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីប្រគល់វិញ្ញាបនបត្រកម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា"

**នារសៀលថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២៣ វេលាម៉ោង ២:០០ រសៀល ដល់ម៉ោង ៥:០០ រសៀល** នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងក្រុមហ៊ុន META បានសហការរៀបចំពិធីប្រគល់វិញ្ញាបនបត្រ **កម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា" ជំនាន់ទី១**។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ឈៀង វណ្ណមុនិណ្ណ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈ-កម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, **លោកបណ្ឌិត ហេង ភក្តី** អ្នកគ្រប់គ្រងគោលនយោបាយសាធារណៈនៃក្រុមហ៊ុន META និងមានការចូលរួមពីសិក្ខាកាម គ្រូបណ្តុះបណ្តាល និងភ្ញៀវកិត្តិយសជាច្រើនទៀត។

**កម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា"** បានទទួលបេក្ខជនដាក់ស្នើពាក្យចូលរួម សរុបប្រមាណ **៦០០ នាក់**។ បន្ទាប់ពីការសម្រិតសម្រាំង, បេក្ខជន **៥០នាក់** ត្រូវបានជ្រើសរើសចូលរួមវគ្គបណ្តុះបណ្តាល នៅក្នុងជំនាន់ទី១នេះ។ វគ្គបណ្តុះបណ្តាល ៨សប្តាហ៍ គឺត្រូវបានប្រព្រឹត្តទៅក្រោមទម្រង់ជាការសិក្សាអនឡាញ និងការសិក្សាក្នុងថ្នាក់រៀន ដែលក្នុងសប្តាហ៍នីមួយៗ សិក្ខាកាមបានទទួលនូវការបង្រៀន និងពន្យល់យ៉ាងក្បោះក្បាយលើប្រធានបទល្អៗ ជាច្រើនពីសំណាក់គ្រូបណ្តុះបណ្តាលជំនាញ ទាំង ៣រូប រួមមាន៖ កញ្ញា គង់ សុវណ្ណ, លោក សូ វណ្ណដាវីដ, និងលោក សួង សំរិត ដែលជាអ្នកគ្រប់គ្រងដំណោះស្រាយអតិថិជននៃក្រុមហ៊ុន Httpool។

ពិធីប្រគល់វិញ្ញាបនបត្រនេះបានប្រកាសបើកដំណើរការដោយ **ឯកឧត្តមបណ្ឌិត ឈៀង វណ្ណមុនិណ្ណ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ ក្នុងការថ្លែងសុន្ទរកថាបើក, **ឯកឧត្តមបណ្ឌិត** បានលើកឡើងថា *"កម្មវិធីបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅដោយរលូន និង ទទួលលទ្ធផលដូចការរំពឹងទុក ដែលក្នុងនោះ ម្ចាស់ និង អ្នកគ្រប់គ្រងសហគ្រាសបានចាប់យកចំណេះដឹងសំខាន់ៗ , គំនិតនវានុវត្តន៍ និង បទពិសោធន៍ជាក់ស្តែងបន្ថែម ពីសំណាក់អ្នកជំនាញផ្នែកទីផ្សារឌីជីថល។ អ្វីដែលទទួល*

*បានពីវគ្គបណ្តុះបណ្តាលនេះនឹងផ្តល់ជាគុណប្រយោជន៍ដល់សហគ្រាសក្នុងការអនុវត្តកិច្ចដំណើរការអាជីវកម្មរបស់ខ្លួន ក៏ដូចជា ការចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលនៅកម្ពុជាផងដែរ។"*

ក្នុងដំណើរការនៃកម្មវិធីនេះដែរ, **លោកបណ្ឌិត ហេង ភក្តី** អ្នកគ្រប់គ្រងគោលនយោបាយសាធារណៈនៃក្រុមហ៊ុន META បានថ្លែងមតិស្វាគមន៍ដោយគូសរំលេចពីសារៈសំខាន់នៃការបង្កើនជំនាញ និងចំណេះដឹងឌីជីថលសម្រាប់សគ្រាសកម្ពុជានៅក្នុងយុគ្គសម័យបច្ចេកវិទ្យាឌីជីថល។ **លោកបណ្ឌិត** ក៏បន្តផ្តល់ជាសំណូមពរ និងលើកទឹកចិត្តដល់សិក្ខាកាម ក្នុងការបន្តចាប់យក និងបំពាក់បំប៉នជំនាញ និង ចំណេះដឹងទីផ្សារឌីជីថលបន្ថែមតាមរយៈវគ្គបណ្តុះបណ្តាលផ្សេងៗទៀត ដើម្បីយកទៅពង្រីក និងប្រតិបត្តិដំណើរការអាជីវកម្មរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។

ជាមួយគ្នានេះដែរ, វាគ្មិនកិត្តិយសដែលជាសិក្ខាកាម និង គ្រូបណ្តុះបណ្តាលក៏បានចូលរួមចែករំលែកបទពិសោធន៍ និង មតិចំណាប់អារម្មណ៍របស់ខ្លួនលើកម្មវិធីបណ្តុះបណ្តាលជុំវគ្គកាលទី១នេះ អម ជាមួយការធ្វើបទបង្ហាញពីលទ្ធផលសម្រេចនៃវគ្គបណ្តុះបណ្តាលជុំវគ្គកាលទី១ និងការណែនាំបន្ថែមអំពីការប្រព្រឹត្តទៅ **កម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាស កម្ពុជា" ជុំវគ្គកាលទី២** ដែលនឹងបើកដំណើរការទទួលពាក្យនាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២៣ ខាងមុខនេះ។

ពិធីប្រគល់វិញ្ញាបនបត្រនេះ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុកថែមទាំងទទួលបានជាតុចូលល្អៗជាច្រើន តាមរយៈការចែករំលែកទស្សនាទាន, គំនិតនវានុវត្តន៍ និងបទពិសោធន៍ជាក់ស្តែងពីវាគ្មិនកិត្តិយស និងអ្នកចូលរួមទាំងអស់។

សូមចូលទៅកាន់គេហទំព័រwww.digitaleconomy.gov.kh/trainings/digital-marketing ដើម្បីស្វែងយល់បន្ថែមពីវគ្គបណ្តុះបណ្តាលជុំវគ្គកាលទី២ និងធ្វើការចុះឈ្មោះ។ សម្រាប់ការស្រាយចម្ងល់ផ្សេងទៀត សូមផ្ញើសារមកកាន់ទំព័រហ្វេសប៊ុកផ្លូវការ

១. គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល - គសធឌ

( www.facebook.com/digitaleconomyandbusinesscommittee )

២. មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

( www.facebook.com/Techo.Startup.Center )។